ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# បទបង្ហាញស្តីពី អំពើជួញដូរមនុស្សនៅកម្ពុជា រយៈពេល៦ខែដើមឆ្នាំ២០១៨

រៀបចំដោយ ប្រតិភូនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

(Cambodia, China, Laos, Myanmar, Thailand and Vietnam

Working Conference of the six countries´ joint action against human trafficking)

២១-២៣ សីហា ២០១៨ ក្រុងគន់មិញ ខេត្តយន់ណាន ប្រទេសចិន

## I. ស្ថានភាពរួម

ប្រទេសកម្ពុជាជាប្រភពឆ្លងកាត់ និងជាគោលដៅនៃអំពើជួញដូរមនុស្ស ដែលជនរងគ្រោះភាគច្រើន ត្រូវបានគេជួញដូរទៅកាន់ប្រទេសមួយចំនួន មានជាអាទិ៍ ប្រទេសថៃ ចិន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ប្រ៊ុយណេ សឹង្ហបុរី ប៉ាគីស្ថាន សូម៉ាលី ជប៉ុន និងអារ៉ាប់ប៊ីសាអូឌីត ។ មេខ្យល់បានប្រើល្បិចកលបោកបញ្ឆោតល្បួងលោម អូសទាញនាំយកចេញដើម្បីកេងប្រវ័ញ្ចកំលាំងពលកម្ម ធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ បំបិតសិទ្ធសេរីភាព បង្ខំឲ្យរៀបអាពាពិពាហ៍ផ្ទុយពីឆន្ទៈ និងធ្វើការងារគ្មានពេលសំរាក។ អ្នកទាំងនោះមានមួយចំនួន បានទំនាក់ទំនងមកក្រុមគ្រួសារ ឬសមត្ថកិច្ចដើម្បីជួយអន្តរាគមន៍យកពួកគេត្រឡប់មកកម្ពុជាវិញ។ ចំណែកអំពើធ្វើអាជីវកម្មផ្លូវភេទវិញ មានការប្រែប្រួលរូបភាព ដោយផ្លាស់ប្តូរគោលដៅទៅតាមតំបន់ជាយរាជធានីភ្នំពេញ ហើយមួយចំនួនទៀតនៅតាមបណ្តាខេត្តជាប់ព្រំដែន ដែលមានជីវភាពរីកចំរើន។

ដោយឡែក បញ្ហាដែលចាប់អារម្មណ៍មួយទៀតនោះគឺ អំពើជួញដូរសរីរាង្គ និងការជួលស្ត្រីឲ្យពរពោះជំនួសដើម្បីសំរាលកូនទៅឲ្យគេ បញ្ហានេះកើតឡើងតាមរយៈអន្តរការីដើម្បីទាញយកផលប្រយោជន៍ពីបុរស ស្ត្រីដែលមានជីវភាពខ្វះខាត។

## II. សង្គ្រោះ និងបង្ក្រាប

### ១. ការបង្ក្រាប

នាយកដ្ឋានជំនាញ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ខិតខំតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្សបាន១៨ករណី ឃាត់ខ្លួនជនសង្ស័យចំនួន២៨នាក់ ស្រី១៤នាក់ ជនបរទេស៣នាក់(សញ្ជាតិចិន) និងបង្ក្រាបអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន៤៤ករណី ឃាត់ខ្លួនជនសង្ស័យចំនួន៥៧នាក់ ស្រី១០នាក់ ជនសង្ស័យជាអនីតិជន៨នាក់និងជនបរទេស១៥នាក់មាន សញ្ជាតិអូស្ត្រាលី១នាក់ កាណាដា២នាក់ អង់គ្លេស៥នាក់ ណកវេស១នាក់ ញ៉ូស៊ីឡែន១នាក់ ហូល្លង់១នាក់ វៀតណាម៣នាក់ និងហ្វីលីពិន១នាក់។

### ២. ការសង្គ្រោះ

អាជ្ញាធរកម្ពុជាបានជួយសង្គ្រោះជនរងគ្រោះ ពីការបង្ក្រាបអំពើជួញដូរមនុស្សបានចំនួន៣២នាក់ ដែលអាយុក្រោម១៥ឆ្នាំ៥នាក់ អាយុ១៥-១៧ឆ្នាំ៤នាក់ អាយុ១៨ឆ្នាំឡើង២៣នាក់ ក្នុងនោះបានប្រគល់ឲ្យមន្ទីរសង្គមកិច្ច៦នាក់ ប្រគល់ឲ្យគ្រួសារ២៦នាក់ និងសង្គ្រោះពីការបង្ក្រាបអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន៧៤នាក់ ដែលអាយុក្រោម១៥ឆ្នាំ៣៧នាក់ អាយុ១៥-១៧ឆ្នាំ៨នាក់ អាយុ១៨ឆ្នាំឡើង២៩នាក់ ក្នុងនោះបានប្រគល់ឲ្យមន្ទីរសង្គមកិច្ច៣៤នាក់ ប្រគល់ឲ្យគ្រួសារ៤០នាក់។

## III. ចរិតលក្ខណៈជួញដូរមនុស្ស

- បណ្តាញជនល្មើស ឬមេខ្យល់ រៀបចំចាត់ចែងបញ្ជូនមនុស្សទៅក្រៅប្រទេស ដោយប្តូររូបភាពពីវិធីសាមញ្ញទៅជារបៀបបិតបាំងព័ត៌មានប្រើមនុស្សផ្តាច់ព័ត៌មានជាកង់ៗដោយមានបញ្ជាពីជនល្មើសក្រៅប្រទេស។
- ជនល្មើស ឬមេខ្យល់ ប្រើប្រាស់ទូរស័ព្ទអត់ចុះឈ្មោះ គ្មានអត្តសញ្ញាណសំគាល់ ដើម្បីទំនាក់ទំនងគ្នាជាប្រព័ន្ធ ធ្វើសកម្មភាពប្រព្រឹត្តបទល្មើស។
- ជនល្មើស ឬមេខ្យល់ ប្រើល្បិចកលលួងលោម ឃោសនា បោកបញ្ឆោត ឲ្យជនរងគ្រោះជឿទុកចិត្តថាគ្មានហានិភ័យ គ្មានគ្រោះថ្នាក់ ហើយទទួលបានលុយច្រើន និងភ្លាមៗ។
- ជនល្មើស ឬមេខ្យល់ ធ្វើបំលាស់ទីជនរងគ្រោះ ពីគោលដៅមួយទៅគោលដៅមួយទៀត តាមមធ្យោបាយជិះរថភ្លើង យន្តហោះ រថយន្តឈ្នួល ឡានក្រុង ជិះម៉ូតូ និងថ្មើជើងតាមច្រករបៀង ដែលមានការរៀបចំចាត់ចែងរួចហើយ មួយចំនួនតាមច្រកព្រំដែនកម្ពុជាឡាវ មួយចំនួនតាមច្រកព្រំដែនកម្ពុជាវៀតណាម និងកម្ពុជាភូមាឬវៀតណាមភូមា ដោយមានអ្នកចាំទទួលនៅប្រទេសគោលដៅ។

- មានការឃោសនា អូសទាញ បោកបញ្ឆោត ទៅធ្វើការនៅប្រទេសវៀតណាម ប្រទេសម៉ាឡេស៊ី ប្រទេសថៃ ឥណ្ឌូនេស៊ី និងប្រទេសចិន។ល។ ទទួលបានប្រាក់ឈ្នួលច្រើន ដោយការធ្វើដំណើរ សោហ៊ុយចាយវាយ ស្នាក់នៅ ហូបចុក ការរៀបចំឯកសារ បែបបទ ជនល្មើសឬមេខ្យល់ជាអ្នកចំណាយមុន ឬឲ្យលុយទៅឪពុកម្តាយជនរងគ្រោះជាការទិញទឹកចិត្ត។
- ជនរងគ្រោះមួយចំនួន បានទទួលប្រាក់ពីមេខ្យល់មុន និងមួយចំនួនទៀត ត្រូវបានមេខ្យល់បង្ខំឲ្យធ្វើតាមដែលប្តូរទៅនិងការឲ្យប្រាក់ខ្ចីជាមុន។

## IV. **បញ្ហាលំបាក**

- ជនរងគ្រោះនៅក្រៅប្រទេស មិនស្គាល់ឈ្មោះទីកន្លែងដែលខ្លួនកំពុងរស់នៅ មិនចេះភាសាទំនាក់ទំនងគ្នា គ្មានលុយក្នុងខ្លួន មិនអាចធ្វើដំណើរទៅណាបានព្រោះលិខិតឆ្លងដែនត្រូវបានគេដកហូត។
- សមត្ថកិច្ចមានព័ត៌មាន និងបណ្តឹងពីក្រុមគ្រួសារជនរងគ្រោះ ។ ករណីខ្លះជនរងគ្រោះបានទូរស័ព្ទមកប្តឹងដោយផ្ទាល់ ក៏សមត្ថកិច្ចមិនអាចជួយអន្តរាគមន៍ចេញពីកន្លែងកើតហេតុទាន់ពេលវេលា។
- ជនរងគ្រោះមួយចំនួនមិនចង់សហការ ផ្តល់ចម្លើយពេញលេញដល់សមត្ថកិច្ច ព្រោះក្រុមគ្រួសារ ឬសាច់ញាតិជាប់ពាក់ព័ន្ធបទល្មើស។
- ករណីខ្លះជនរងគ្រោះមិនសហការជាមួយសមត្ថកិច្ច បណ្តាលមកពីមូលហេតុជនល្មើសបានគំរាមកំហែងជនរងគ្រោះ ឬគំរាមកំហែងដល់ក្រុមគ្រួសារថានឹងសំលាប់ចោល ទារយកលុយវិញ ឬប្តឹងបកវិញ។

## V. **សំណូមពរ**

- ស្នើពង្រឹងកិច្ចសហការ និងសហប្រតិបត្តិការរវាងជនបង្គោលនិងជនបង្គោលក្នុងគោលបំណងដើម្បីជួយអន្តរាគមន៍សង្គ្រោះជនរងគ្រោះ និងបង្ក្រាបជនប្រព្រឹត្តបទល្មើស។
- ស្នើភាគីចិន រឹតបន្តឹងការផ្តល់ទិដ្ឋាការដល់នារីវ័យក្មេងកម្ពុជា ទោះនៅប្រទេសណាក៏ដោយ។
- ស្នើសមត្ថកិច្ចពាក់ព័ន្ធ នៅតាមបណ្តោយព្រំដែននៃប្រទេសនិមួយៗ ក្នុងបណ្តាប្រទេសអនុតំបន់មេគង្គខមមីត រឹតបន្តឹងការឆ្លងដែនដោយគ្មានឯកសារឆ្លងដែនគ្រប់គ្រាន់។
- ស្នើឲ្យមានកិច្ចប្រជុំផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ទៅវិញទៅមក ៣ខែម្តង ឬ៦ខែម្តង ក្នុងករណីចាំបាច់អាចមានកិច្ចប្រជុំពិសេស។
- ស្នើឲ្យមានការបណ្តុះបណ្តាល ឬសិក្ខាសាលារួមគ្នាសំរាប់អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងអនុតំបន់មេគង្គ។